សុន្ទរកថារបស់ **ឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា**

ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ

**១៦ ធ្នូ ២០១៦**

- សូមគោរព **ឯកឧត្តម ពេជ្រ វាសនា** អគ្គនាយករងកិច្ចការរដ្ឋបាលនៃក្រសួងធនធានទឹក និងឧតុនិយម
- សូមគោរព **វេជ្ជបណ្ឌិត កែវ សុភ័ក្រ្តា** ប្រធានមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ
- សូមគោរព **លោក អ៊ុម វិបុល** ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ចាម
- សូមគោរព **លោក លៀង សេង** ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តស្ទឹងត្រែង
- សូមគោរព **លោក អ៊ាត សារ៉ាត់** អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តប៉ៃលិន
- សូមគោរព អស់លោក លោកស្រី!

ខ្ញុំមានសេចក្តីសប្បាយរីករាយ ដែលបានប្រារព្ធពិធីចុះហត្ថលេខានៅថ្ងៃនេះ លើកិច្ចសន្យាផ្តល់ជំនួយចំនួន៤ សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។

គម្រោងជំនួយទី១ ដែលមានថវិកាចំនួន៨២,១៤៥ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់អគារផ្នែកសម្ភព និងកុមារ នៅមន្ទីរពេទ្យបង្អែកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។ គម្រោងសាងសង់អគារថ្មីនេះ នឹងបែងចែកបន្ទប់ផ្នែកសម្ភព និងផ្នែកជម្ងឺកុមារ បន្ទប់សម្រាលកូន និងបន្ទប់ពិគ្រោះជម្ងឺ។ គម្រោងនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់អ្នកជម្ងឺផ្នែកកុមារប្រមាណជា ១,៩០០នាក់ និងស្ត្រីមានផ្ទៃពោះ និងទារកប្រមាណជា ៣៦០នាក់ អោយទទួលបាននូវសេវាសុខភាពកាន់តែល្អប្រសើរជាងមុន។

គម្រោងជំនួយទី២ ដែលមានថវិកាចំនួន៨២,៥២៤ដុល្លារអាមេរិក សម្រាប់គម្រោងស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រវាលស្តៅ ខេត្តកំពង់ចាម។ គម្រោងនេះរួមមាន៖ ការស្តារទំនប់១ខ្សែ ផ្លូវភ្ជាប់ទំនប់១ខ្សែ សំណង់ទ្វារទឹក២កន្លែង និងលូទឹក៨កន្លែង។ ជាមួយនឹងគម្រោងនេះ កសិករប្រមាណជា៣,៥០០នាក់ នឹងទទួលបានទឹកគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ ក្រោយពីបញ្ចប់គម្រោងនេះ។

គម្រោងជំនួយទី៣ ដែលមានថវិកាចំនួន៨៣,០០០ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់អគារមជ្ឈមណ្ឌលសហគមន៍កសិកម្ម ខេត្តស្ទឹងត្រែង។ គម្រោងនេះ នឹងសាងសង់អគារមជ្ឈមណ្ឌលសហគមន៍កសិកម្ម៣កន្លែង សម្រាប់សហគមន៍កសិកម្មចំនួន៣ និងផ្តល់ជូននូវម៉ាស៊ីនកសិកម្មមួយចំនួនផងដែរ។ កសិករប្រមាណជា ៨០០នាក់ នឹងទទួលបានប្រយោជន៍ពីគម្រោងនេះ។

គម្រោងជំនួយទី៤ ដែលមានថវិកាចំនួន៨២,៦០០ដុល្លារអាមេរិក សម្រាប់គម្រោងកែលម្អផ្លូវក្នុងភូមិប៉ាងរលឹម ឃុំអូរតាវ៉ៅ ខេត្តប៉ៃលិន។ គម្រោងនេះ នឹងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់ប្រជាជនប្រមាណជា ៤,៣០០នាក់នៅក្នុងតំបន់នេះ។ ខ្ញុំសង្ឃឹមថា ការកែលម្អផ្លូវនេះ នឹងជួយលើកស្ទួយសេដ្ឋកិច្ចក្នុងស្រុក តាមរយៈការផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើរទៅសាលារៀន មន្ទីរពេទ្យ ផ្សារ និងតំបន់ផ្សេងទៀត។

ខ្ញុំសង្ឃឹមថា គម្រោងទាំង៤នេះ នឹងត្រូវបានអនុវត្តយ៉ាងរលូន និងមានប្រសិទ្ធិភាពខ្ពស់ជាមួយនឹងដៃគូទទួលជំនួយរបស់យើង។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សំណង់ និងម៉ាស៊ីនកសិកម្មទាំងអស់ដែលត្រូវបានសាងសង់ និងផ្តល់ជូនដោយគម្រោងទាំងនេះ នឹងត្រូវបានថែទាំអោយបានល្អ និងយូរអង្វែង ដើម្បីអោយប្រជាជនកាន់តែច្រើនអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាគម្រោងទាំងនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាព ដែលមានរួចមកហើយរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណ!**